**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**


**ប្រធានគណៈមេធាវី**

**មេធាវី ប៊ុន ហុន**

**ក្រុមប្រឹក្សាគណៈមេធាវី**

១-មេធាវី សាំង វណ្ណៈ
២-មេធាវី អ៊ឹង គិរិយា
៣-មេធាវី កែត ឃី
៤-មេធាវី អ៊ីវ ប៉ូលី
៥-មេធាវី ខៀវ សំបូរ
៦-មេធាវី ជា សុកនួន
៧-មេធាវី សាន់ ជួយ
៨-មេធាវី ថាន ផានិត
៩-មេធាវី ជូ ចាន់ធីរ៉ា
១០-មេធាវី កេង សុម៉ាឡា
១១-មេធាវី ម៉ី ឧសភា
១២-មេធាវី សេង សុខឃីម
១៣-មេធាវី លីវ សុវណ្ណា
១៤-មេធាវី ឈីវ គិរម្យ
១៥-មេធាវី សំ សុគង់
១៦-មេធាវី នង មានន្ទ
១៧-មេធាវី អ៊ូ ធីតាពៅ
១៨-មេធាវី លី ពីង
១៩-មេធាវី យឹម វិស្សុត
២០-មេធាវី លឹម ច័ន្ទលីដា
២១-មេធាវី កែ វិសាល
២២-មេធាវី ហូ លីហួរ
២៣-មេធាវី វ៉ា ពិសី
២៤-មេធាវី ជា ហុងរី
២៥-មេធាវី សៅ កញ្ញា
២៦-មេធាវី ម៉ុន វិមានចំប៉ា
២៧-មេធាវី ឈី សម្បត្តិ


លេខ : ០០៤ /សសគម/១៦

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមករា ឆ្នាំ២០១៦

# សេចក្តីសម្រេច
# ស្តីពី
# ការគ្រប់គ្រងការប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេស

## ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១២ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី៧
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **ប៊ុន ហុន** ជាប្រធានគណៈមេធាវីអាណត្តិទី ១០
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៨
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវីនាសម័យប្រជុំថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៥

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ប្រការ ១. គោលបំណង

សេចក្តីសម្រេចនេះមានគោលបំណងកំណត់អំពីគោលការណ៍ លក្ខខណ្ឌ វិសាលភាព និងទម្រង់នៃការប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាបាននូវគុណភាពនៃការផ្តល់សេវាកម្មច្បាប់ការពារផលប្រយោជន៍ស្របច្បាប់របស់សាធារណជន និងចូលរួមពង្រឹងនីតិរដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។



អគារស្ថិតនៅកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ៖១៥៨៧ , ទូរស័ព្ទ: (៨៥៥-២៣) ៨៦៤ ០៧៨
ទូរសារ: (៨៥៥-២៣) ៨៦៤ ០៧៦, E-mail: info@bakc.org.kh, website: www.bakc.org.kh

**ប្រការ ២. វិសាលភាពនៃការអនុវត្ត**

សេចក្តីសម្រេចនេះមានវិសាលភាពអនុវត្តចំពោះគ្រប់មេធាវីបរទេស និងក្រុមហ៊ុនមេធាវីបរទេស ទាំងអស់ដែលមានបំណងប្រកបវិជ្ជាជីវៈមេធាវីនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែមេធាវីបរទេសដែលបម្រើការងារនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិដោយឡែក។

**ប្រការ ៣. និយមន័យនៃពាក្យបច្ចេកទេស**

- **គណៈមេធាវី** សំដៅដល់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។
- **មេធាវីបរទេស** សំដៅដល់ជនបរទេសដែលបានចុះបញ្ជីត្រឹមត្រូវជាមេធាវី នៅក្នុងគណៈមេធាវីនៃប្រទេសកំណើត ឬប្រទេសដទៃក្រៅពីព្រះរាជាណាចក្រកម្ពុជា។
- **ក្រុមហ៊ុនមេធាវីបរទេស** សំដៅដល់ក្រុមហ៊ុនមេធាវីដែលបង្កើតឡើងក្រោមច្បាប់នៃប្រទេសណាមួយក្រៅពីព្រះរាជាណាចក្រកម្ពុជា។
- **ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស** សំដៅដល់ក្រុមហ៊ុនមេធាវីដែលបង្កើតឡើងស្របតាមសេចក្តីសម្រេចនេះ ហើយមានម្ចាស់ភាគហ៊ុនជាមេធាវីខ្មែរ និងមេធាវីបរទេស ដែលក្នុងនោះមេធាវីខ្មែរកាន់កាប់ភាគហ៊ុនជាក់ស្តែងនិងពិតប្រាកដ និងមានសិទ្ធិបោះឆ្នោតចំនួនចាប់ពី ៥១ (ហាសិបមួយ) ភាគរយ ឡើងទៅ។
- **កិច្ចសហការផ្តល់សេវាកម្មច្បាប់** សំដៅដល់កិច្ចសហការរវាងក្រុមហ៊ុនមេធាវីបរទេស និងក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ឬការិយាល័យវិជ្ជាជីវៈមេធាវីខ្មែរ ដែលបានទទួលការយល់ព្រមពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ២

## ការចុះបញ្ជី និងការប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេស

**ប្រការ ៤. ការចុះបញ្ជី និងវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវី**

មេធាវីបរទេសមិនអាចប្រកបវិជ្ជាជីវៈមេធាវីនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានទេ ប្រសិនបើមិនបានចុះបញ្ជីនៅគណៈមេធាវី និងមិនមានវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីនៅមានសុពលភាព។

វិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេសកំណត់អំពីវិសាលភាពនៃសេវាកម្មច្បាប់ដែលផ្តល់ដោយមេធាវីបរទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៥. លក្ខខណ្ឌ**

មេធាវីបរទេសដែលអាចដាក់ពាក្យស្នើសុំចុះបញ្ជីនៅគណៈមេធាវី ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១. ត្រូវជាមេធាវីពេញសិទ្ធិដែលប្រកបវិជ្ជាជីវៈមេធាវី និងមានបទពិសោធន៍ក្នុងការប្រកបវិជ្ជាជីវៈមេធាវីនៅគណៈមេធាវីដែលខ្លួនបានចុះបញ្ជី យ៉ាងហោចណាស់ ៥ (ប្រាំ) ឆ្នាំ

២. អាជ្ញាធរមានសមត្ថកិច្ច ឬគណៈមេធាវីដែលខ្លួនបានចុះបញ្ជី ត្រូវផ្តល់លទ្ធភាពដូចគ្នាដល់មេធាវីខ្មែរ

៣. ត្រូវមានកាយសម្បទាគ្រប់គ្រាន់ និងសីលធម៌ល្អ

៤. មិនធ្លាប់ទទួលទណ្ឌកម្មរដ្ឋបាល ឬផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ និង

៥. មិនធ្លាប់ត្រូវបានប្រកាសក្ស័យធនផ្ទាល់ខ្លួន ។

**ប្រការ ៦. ពាក្យស្នើសុំចុះបញ្ជីរបស់មេធាវីបរទេស**

មេធាវីបរទេសអាចដាក់ពាក្យស្នើសុំចុះបញ្ជីមកគណៈមេធាវី ដោយត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

១. ពាក្យស្នើសុំចុះបញ្ជីដែលត្រូវចុះហត្ថលេខាផ្ទាល់ដោយមេធាវីបរទេសដែលបានដាក់ពាក្យស្នើសុំ ។

២. ប្រវត្តិរូបសង្ខេប ។

២. លិខិតបញ្ជាក់សមាជិកភាព នៅក្នុងគណៈមេធាវីនៃប្រទេសណាមួយ (ច្បាប់ដើម) ។

៣. លិខិតបញ្ជាក់អំពីបទពិសោធន៍នៃការប្រកបវិជ្ជាជីវៈមេធាវីលើសពី ៥ (ប្រាំ) ឆ្នាំ (ច្បាប់ដើម) ។

៤. អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈមេធាវីដែលនៅមានសុពលភាព ចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៅក្នុងប្រទេសណាមួយ (សេចក្តីចម្លងដែលមានបញ្ជាក់ថាបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម) ។

៥. ច្បាប់ ឬបទប្បញ្ញត្តិដែលគ្រប់គ្រងលើវិជ្ជាជីវៈមេធាវីនៃប្រទេសដែលមេធាវីបរទេសបានចុះបញ្ជី (សេចក្តីចម្លងដែលមានបញ្ជាក់ថាបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម) ។

៦. ក្រមសីលធម៌មេធាវីនៃប្រទេសដែលមេធាវីបរទេសបានចុះបញ្ជី (សេចក្តីចម្លងដែលមានបញ្ជាក់ថាបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម) ។

៧. លិខិតឆ្លងដែន និងទិដ្ឋាការនៅមានសុពលភាព (សេចក្តីចម្លងដែលមានបញ្ជាក់ថាបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម) ។

៨. លិខិតថ្កោលទោស ។

៩. ឯកសារផ្សេងទៀតដែលតម្រូវដោយគណៈមេធាវី ។

ឯកសារទាំងអស់ដូចមានចែងក្នុងកថាខណ្ឌខាងលើ ត្រូវបកប្រែជាភាសាខ្មែរ ។

**ប្រការ ៧. ការពិនិត្យសមត្ថភាព**

ក្រុមប្រឹក្សាគណៈមេធាវីអាចសម្រេចឱ្យមេធាវីបរទេសធ្វើការប្រឡងលើមុខវិជ្ជាគ្រឹះចំនួន ២ (ពីរ) គឺ គោលការណ៍ទូទៅផ្នែកច្បាប់កម្ពុជា និងវិធានវិជ្ជាជីវៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មុននឹងសម្រេចឱ្យចុះបញ្ជីនៅគណៈមេធាវី ។

បែបបទ និងនីតិវិធីនៃការប្រឡងត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ។

**ប្រការ ៨. ការធ្វើសច្ចាប្រណិធាន**

បន្ទាប់ពីត្រូវបានសម្រេចអនុញ្ញាតឱ្យចុះបញ្ជីនៅគណៈមេធាវី មេធាវីបរទេសត្រូវធ្វើសច្ចាប្រណិធាននៅចំពោះមុខសាលាឧទ្ធរណ៍រាជធានីភ្នំពេញ មុនពេលប្រកបវិជ្ជាជីវៈមេធាវីរបស់ខ្លួន។

**ប្រការ ៩. វិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេស**

មេធាវីបរទេសត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេស ដើម្បីកំណត់អំពីវិសាលភាពនៃការប្រកបវិជ្ជាជីវៈមេធាវីរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

វិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេសនេះមានសុពលភាព ១ (មួយ) ឆ្នាំ ហើយអាចបន្តទៀតបាន ប្រសិនបើមេធាវីបរទេសអនុវត្តស្របទៅតាមលក្ខខណ្ឌដែលមានកំណត់នៅក្នុងសេចក្ដីសម្រេចនេះ។

មេធាវីបរទេស ត្រូវដាក់ពាក្យស្នើសុំបន្តវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេសមកគណៈមេធាវី ឱ្យបានយ៉ាងហោចណាស់ ៣០ (សាមសិប) ថ្ងៃ មុនពេលវិញ្ញាបនបត្រផុតសុពលភាព។

**ប្រការ ១០. ការតំណាងកូនក្ដី**

មេធាវីបរទេសអាចអមមេធាវីខ្មែរ ប៉ុន្តែមិនអាចតំណាងកូនក្ដីដោយផ្ទាល់នៅចំពោះមុខតុលាការ ឬស្ថាប័នសាធារណៈដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជាបានឡើយ។

## ជំពូកទី ៣

## ទម្រង់នៃការប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេស និងការចុះបញ្ជីក្រុមហ៊ុនមេធាវីបរទេស និងក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស

**ប្រការ ១១. ទម្រង់នៃការប្រកបវិជ្ជាជីវៈមេធាវី**

មេធាវីបរទេសអាចប្រកបវិជ្ជាជីវៈរបស់ខ្លួនក្នុងទម្រង់ដូចខាងក្រោម៖

១. ក្រុមហ៊ុនមេធាវីបរទេស។

២. ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស។

**ប្រការ ១២. ក្រុមហ៊ុនមេធាវីបរទេស**

ក្រុមហ៊ុនមេធាវីបរទេសអាចផ្ដល់សេវាកម្មច្បាប់លើច្បាប់បរទេស និងច្បាប់អន្តរជាតិ ប៉ុន្តែមិនអាចផ្ដល់សេវាកម្មច្បាប់លើច្បាប់កម្ពុជាបានទេ លើកលែងតែមានកិច្ចសហការផ្ដល់សេវាកម្មច្បាប់ស្របតាមជំពូកទី ៥ នៃសេចក្ដីសម្រេចនេះ។

**ប្រការ ១៣. ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស**

ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស អាចផ្ដល់សេវាកម្មច្បាប់លើច្បាប់កម្ពុជា ច្បាប់បរទេស និងច្បាប់អន្តរជាតិបាន។ មេធាវីបរទេសដែលជាម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុន អាចផ្ដល់សេវាកម្មច្បាប់លើច្បាប់កម្ពុជាបាន តែត្រូវស្ថិតក្រោមការដឹកនាំ ត្រួតពិនិត្យ និងទទួលខុសត្រូវរបស់មេធាវីដែលជាម្ចាស់ភាគហ៊ុនខ្មែរ។

**ប្រការ ១៤. ការចុះបញ្ជី**

ក្រុមហ៊ុនមេធាវីបរទេស ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីមកគណៈមេធាវី ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

១. ពាក្យស្នើសុំចុះបញ្ជី ដែលត្រូវចុះហត្ថលេខាដោយមេធាវីតំណាងស្របច្បាប់របស់ក្រុមហ៊ុន។

២. មេធាវីតំណាងស្របច្បាប់របស់ក្រុមហ៊ុន ត្រូវបំពេញលក្ខខណ្ឌ និងចុះបញ្ជីនៅគណៈមេធាវី ស្របតាមជំពូកទី ២ នៃសេចក្តីសម្រេចនេះ។

៣. លិខិតបញ្ជាក់ការតម្កល់ដើមទុនអប្បបរមា ១ ០០០ ០០០ ០០០ (មួយពាន់លាន) រៀល ចេញដោយធនាគារណាមួយនៃព្រះរាជាណាចក្រកម្ពុជា។

៤. ផែនការអាជីវកម្មរយៈពេល ៣ (បី) ឆ្នាំ របស់ក្រុមហ៊ុន។

៥. លក្ខន្តិកៈក្រុមហ៊ុនដែលចុះហត្ថលេខាដោយមេធាវីជាម្ចាស់ភាគហ៊ុន។

៦. លក្ខន្តិកៈក្រុមហ៊ុនមេធាវីបរទេសជាម្ចាស់ភាគហ៊ុន វិញ្ញាបនបត្រចុះបញ្ជី អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ និងរបាយ-ការណ៍ហិរញ្ញវត្ថុរយៈពេល ៣ (បី) ឆ្នាំចុងក្រោយ (សេចក្តីចម្លងដែលមានបញ្ជាក់ថាបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម)។

៧. លិខិតផ្ទេរសិទ្ធិពីក្រុមហ៊ុនមេធាវីបរទេស ឱ្យមេធាវីបរទេសណាមួយធ្វើជាតំណាងស្របច្បាប់ក្នុងការគ្រប់គ្រងសាខារបស់ក្រុមហ៊ុន។

៨. លិខិតបញ្ជាក់ពីកេរ្តិ៍ឈ្មោះ (Good Standing) របស់ក្រុមហ៊ុនមេធាវីបរទេសជាម្ចាស់ភាគហ៊ុន។

ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីមកគណៈមេធាវី ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

១. ពាក្យស្នើសុំចុះបញ្ជី ដែលត្រូវចុះហត្ថលេខាដោយមេធាវីតំណាងស្របច្បាប់របស់ក្រុមហ៊ុន។

២. មេធាវីបរទេសជាម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុន ត្រូវបំពេញលក្ខខណ្ឌ និងចុះបញ្ជីនៅគណៈមេធាវី ស្របតាមជំពូកទី ២ នៃសេចក្តីសម្រេចនេះ។

៣. លិខិតបញ្ជាក់ការតម្កល់ដើមទុនអប្បបរមា ៤០០ ០០០ ០០០ (បួនរយលានរៀល) ចេញដោយធនាគារណាមួយនៃព្រះរាជាណាចក្រកម្ពុជា។

៤. លក្ខន្តិកៈក្រុមហ៊ុនដែលចុះហត្ថលេខាដោយមេធាវីជាម្ចាស់ភាគហ៊ុន។

**ប្រការ ១៥. លក្ខន្តិកៈក្រុមហ៊ុន**

លក្ខន្តិកៈក្រុមហ៊ុនមេធាវីបរទេស និងក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ត្រូវមានចែងអំពីព័ត៌មានអប្បបរមាដូចខាងក្រោម៖

១. នាមករណ៍ក្រុមហ៊ុន។

២. អាសយដ្ឋានរបស់ក្រុមហ៊ុន។

៣. ឈ្មោះម្ចាស់ភាគហ៊ុន និងចំណែកភាគហ៊ុន។

៤. អ្នកតំណាងស្របច្បាប់របស់ក្រុមហ៊ុន។

៥. កម្មវត្ថុនៃសេវាកម្មច្បាប់ និងវិស័យច្បាប់ដែលក្រុមហ៊ុនមានបំណងប្រកបវិជ្ជាជីវៈ។

៦. រចនាសម្ព័ន្ធ ការគ្រប់គ្រងក្រុមហ៊ុន និងទំនាក់ទំនងរវាងម្ចាស់ភាគហ៊ុន។

៧. គណនេយ្យ និងសវនកម្ម។

៨. ការផ្ទេរ និងអនុប្បទានភាគហ៊ុន។

៩. ការជម្រះបញ្ជី និងការរំលាយក្រុមហ៊ុន។

១០.ការដោះស្រាយវិវាទរវាងម្ចាស់ភាគហ៊ុន តាមយន្តការនៃការផ្សះផ្សាដោយប្រធានគណៈមេធាវី។

**ប្រការ ១៦. ការពិនិត្យ និងសម្រេចលើពាក្យស្នើសុំចុះបញ្ជី**

ក្រុមប្រឹក្សាគណៈមេធាវីត្រូវពិនិត្យ និងសម្រេចលើពាក្យស្នើសុំចុះបញ្ជីក្រុមហ៊ុនមេធាវីបរទេស និងក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យសុំចុះបញ្ជី និងឯកសារភ្ជាប់គ្រប់គ្រាន់។

**ប្រការ ១៧. វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនមេធាវីបរទេស និងក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស**

វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនមេធាវីបរទេស និងក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស មានសុពលភាព ១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចអនុញ្ញាតឱ្យចុះបញ្ជី។

តំណាងស្របច្បាប់របស់ក្រុមហ៊ុនមេធាវីបរទេស ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ត្រូវដាក់ពាក្យស្នើសុំបន្តចុះបញ្ជីក្រុមហ៊ុនមេធាវីបរទេស ឬក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស មកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឱ្យបានយ៉ាងហោចណាស់ ៣០ (សាមសិប) ថ្ងៃ មុនពេលវិញ្ញាបនបត្រចុះបញ្ជីផុតសុពលភាព។

## ជំពូកទី ៤

## ការព្យួរ ការដកហូតវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេស និងវិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនមេធាវីបរទេស ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស និងការលុបឈ្មោះមេធាវីបរទេស

**ប្រការ ១៨. ភាគពុកិច្ចរបស់មេធាវីបរទេស ក្រុមហ៊ុនមេធាវីបរទេស និងក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស**

មេធាវីបរទេសត្រូវមានកាតព្វកិច្ចបង់ភាគទានជូនគណៈមេធាវីចំនួន ១ ២០០ ០០០ (មួយលានពីរសែន) រៀលក្នុងមួយត្រីមាស។

មេធាវីបរទេស ក្រុមហ៊ុនមេធាវីបរទេស និងក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ដែលបានចុះបញ្ជីនៅគណៈមេធាវី ត្រូវអនុវត្តស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី ក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចផ្សេងៗរបស់គណៈមេធាវី ច្បាប់និងបទប្បញ្ញត្តិជាធរមានផ្សេងទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ១៩. ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេស**

វិញ្ញាបនប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេសអាចត្រូវបានព្យួរ ឬត្រូវបានដកហូតក្នុងករណីដែលមេធាវីបរទេសបានប្រព្រឹត្តបំពានទៅនឹង រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី ក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចផ្សេងៗរបស់គណៈមេធាវី ច្បាប់និងបទប្បញ្ញត្តិជាធរមានផ្សេងទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២០. ការលុបឈ្មោះចេញពីបញ្ជីមេធាវីបរទេស**

មេធាវីបរទេសអាចត្រូវបានលុបឈ្មោះចេញពីបញ្ជីមេធាវីបរទេសនៅគណៈមេធាវី ក្នុងករណីដូចខាងក្រោម៖

១. ត្រូវបានលុបឈ្មោះចេញពីគណៈមេធាវីដើមរបស់ខ្លួន។

២. ទទួលមរណភាព ឬពិការភាពមិនអាចអនុវត្តវិជ្ជាជីវៈមេធាវីបាន។

៣. ខកខានមិនបានស្នើសុំវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីរយៈពេល ១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃអនុញ្ញាតឱ្យចុះបញ្ជី។

៤. មិនបំពេញកាតព្វកិច្ចបង់ភាគទានជូនគណៈមេធាវី ២ (ពីរ) ត្រីមាស។

៥. ត្រូវបានសម្រេចលុបឈ្មោះចេញពីបញ្ជីមេធាវីបរទេស ដោយក្រុមប្រឹក្សាគណៈមេធាវី ដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

**ប្រការ ២១. ការព្យួរ និងការដកហូតលិខិតអនុញ្ញាតចុះបញ្ជី**

លិខិតអនុញ្ញាតចុះបញ្ជីរបស់ក្រុមហ៊ុនមេធាវីបរទេស ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស អាចត្រូវបានព្យួរ ឬដកហូត ក្នុងករណីខាងក្រោម៖

១. មេធាវីបរទេសដែលជាតំណាងក្រុមហ៊ុនមេធាវីបរទេស ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ត្រូវបានលុបឈ្មោះចេញពីបញ្ជីមេធាវីបរទេសនៅគណៈមេធាវី ហើយពុំមានអ្នកជំនួសក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ។

២. ក្រុមហ៊ុនមេធាវីបរទេស ក្រុមហ៊ុនមេធាវីបរទេសជាម្ចាស់ភាគហ៊ុន ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ត្រូវបានប្រកាសក្ស័យធន។

៣. ក្រុមហ៊ុនមេធាវីបរទេស ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ត្រូវបានផ្តន្ទាទោសពីបទល្មើសមជ្ឈិម ឬបទល្មើសឧក្រិដ្ឋ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៤. ក្រុមហ៊ុនមេធាវីបរទេស ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស បានផ្តល់ព័ត៌មានមិនពិត ឬ លាក់បាំងការពិត សម្រាប់ការស្នើសុំចុះបញ្ជី ឬ កែប្រែលក្ខន្តិកៈ ឈ្មោះ អាសយដ្ឋាន ឬ ម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុន ឬ សកម្មភាពរបស់ក្រុមហ៊ុន ត្រូវបានហាមឃាត់ដោយតុលាការ ។

ក្រុមហ៊ុនមេធាវីបរទេស ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ដែលការអនុញ្ញាតចុះបញ្ជីត្រូវបានដកហូត ត្រូវធ្វើការជម្រះបញ្ជីតាមច្បាប់ជាធរមាន ។

## ជំពូកទី ៥

## ការគ្រប់គ្រង និងត្រួតពិនិត្យការប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេស

### ប្រការ ២២. សិទ្ធិអំណាចរបស់គណៈមេធាវី

គណៈមេធាវីជាស្ថាប័នតែមួយគត់ដែលគ្រប់គ្រងការប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេស ក្រុមហ៊ុនមេធាវីបរទេស និងក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ។

ក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ និងដោះស្រាយលើគ្រប់បញ្ហាដែលពាក់ព័ន្ធនឹងការប្រកបវិជ្ជាជីវៈមេធាវីរបស់មេធាវីបរទេស ក្រុមហ៊ុនមេធាវីបរទេស និងក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ។

### ប្រការ ២៣. ការធ្វើអធិការកិច្ច

ក្រុមអធិការកិច្ចរបស់គណៈមេធាវីមានសិទ្ធិចូលត្រួតពិនិត្យ សាកសួរ និងស្រាវជ្រាវក្នុងទីស្នាក់ការរបស់ក្រុមហ៊ុនមេធាវីបរទេស ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ឬទីកន្លែងដែលសង្ស័យថាមានការលួចប្រកបវិជ្ជាជីវៈមេធាវីដោយជនបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

### ប្រការ ២៤. កិច្ចសហការផ្តល់សេវាកម្មច្បាប់

រាល់កិច្ចសន្យាសហការផ្តល់សេវាកម្មច្បាប់ ត្រូវតែដាក់ជូនក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ និងយល់ព្រម ។

ក្រុមហ៊ុនមេធាវីបរទេសទាំងអស់ត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ ពាក់ព័ន្ធនឹងកិច្ចសហការផ្តល់សេវាកម្មច្បាប់ ដាក់ជូនគណៈមេធាវី ។

របាយការណ៍ដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះ ត្រូវមានព័ត៌មានពាក់ព័ន្ធនឹង៖

១. ឈ្មោះរបស់ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ឬការិយាល័យវិជ្ជាជីវៈមេធាវីខ្មែរ ដែលធ្វើសហការផ្តល់សេវាកម្មច្បាប់ ។

២. ឈ្មោះមេធាវីទទួលបន្ទុកក្នុងការផ្តល់សេវាកម្ម ។

៣. វិសាលភាពនៃការផ្តល់សេវាកម្មច្បាប់ ។

## ជំពូកទី ៦

## កម្រៃសេវាក្នុងការចុះបញ្ជី

### ប្រការ ២៥. កម្រៃដាក់ពាក្យស្នើសុំ

មេធាវីបរទេសត្រូវបង់ថ្លៃដាក់ពាក្យស្នើសុំចុះបញ្ជី និងសោហ៊ុយអង្កេត តាមដាន និងដំណើរការនីតិវិធីជូនគណៈមេធាវី ដូចខាងក្រោម៖

១. ពាក្យស្នើសុំតម្លៃ ២០០ ០០០ (ពីរសែន) រៀល។

២. សោហ៊ុយអង្កេត តាមដាន និងដំណើរការនីតិវិធី ចំនួន ២ ០០០ ០០០ (ពីរលាន) រៀល។

ក្រុមហ៊ុនមេធាវីបរទេស និងក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ត្រូវបង់ថ្លៃពាក្យស្នើសុំចុះបញ្ជី និងសោហ៊ុយអង្កេត តាមដាន និងដំណើរការនីតិវិធីជូនគណៈមេធាវី ដូចខាងក្រោម៖

១. ពាក្យស្នើសុំតម្លៃ ៤០០ ០០០ (បួនសែន) រៀល។

២. សោហ៊ុយអង្កេត តាមដាន និងដំណើរការនីតិវិធី ចំនួន ៤ ០០០ ០០០ (បួនលាន) រៀល។

ថ្លៃពាក្យស្នើសុំ និងសោហ៊ុយអង្កេត តាមដាន និងដំណើរការនីតិវិធី ដូចមានចែងខាងលើ មិនត្រូវបានប្រគល់ឱ្យវិញទេ ទោះបីជាមិនត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីនៅគណៈមេធាវីក៏ដោយ។

### ប្រការ ២៦. កម្រៃចុះបញ្ជី និងបន្តការចុះបញ្ជី

បន្ទាប់ពីមានការសម្រេចអនុញ្ញាតឱ្យចុះបញ្ជី មេធាវីបរទេស ក្រុមហ៊ុនមេធាវីបរទេស និងក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ត្រូវបង់ថ្លៃចុះបញ្ជី និងស្នើសុំវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈ ជូនគណៈមេធាវី ដូចខាងក្រោម៖

១. មេធាវីបរទេស ២ ០០០ ០០០ (ពីរលាន) រៀល សម្រាប់រយៈពេល ១ (មួយ) ឆ្នាំ។

២. ក្រុមហ៊ុនមេធាវីបរទេស ២០ ០០០ ០០០ (ម្ភៃលាន) រៀល សម្រាប់រយៈពេល ១ (មួយ)ឆ្នាំ។

៣. ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ១០ ០០០ ០០០ (ដប់លាន) រៀល សម្រាប់រយៈពេល ១ (មួយ) ឆ្នាំ។

## ជំពូកទី ៧

## ទោសប្បញ្ញត្តិ

### ប្រការ ២៧. ទណ្ឌកម្មវិន័យ និង ការដាក់ពិន័យ

ជនណាដែលប្រកបវិជ្ជាជីវៈមេធាវីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយពុំបានចុះបញ្ជីនៅគណៈមេធាវី និង/ឬ គ្មានវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវី និង/ឬ មានវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវីហួសសុពលភាព ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ក្រុមហ៊ុនមេធាវីបរទេស ក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ដែលបានប្រព្រឹត្តបំពាននឹងបញ្ញត្តិណាមួយនៃសេចក្តីសម្រេចនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន។

## ជំពូកទី ៨

## អន្តរប្បញ្ញត្តិ

**ប្រការ ២៨. ការកែតម្រូវ**

មេធាវីបរទេស ក្រុមហ៊ុនមេធាវីបរទេស ឬក្រុមហ៊ុនមេធាវីចម្រុះខ្មែរ-បរទេស ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជី និងស្នើសុំវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈមេធាវី ស្របតាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងសេចក្តីសម្រេចនេះ ក្នុងរយៈពេល ៦០ (ហុបសិប) ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចនេះ។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**ប្រការ ២៩. និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៣០. ការអនុវត្ត**

អគ្គលេខាធិការ អគ្គហេរញ្ញិក ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានអធិការកិច្ច ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**មេធាវី.ប៊ុន_ហុន**

**ចម្លងជូន៖**

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

“ដើម្បីជូនជ្រាបដ៏ខ្ពង់ខ្ពស់”

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងយុត្តិធម៌

-ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

-ក្រុមប្រឹក្សាគណៈមេធាវី

“ដើម្បីជូនជ្រាប”

-ឯកសារ-កាលប្បវត្តិ